# កុំឆ្លងស្ពានទេះ

[វត្តជួសជុលនិងថែទាំ។]



Translator Lim Horhok

絵①

កាលពីព្រេងនាយ នៅវត្តក្នុងភូមិមួយ

មានកូននេនមួយអង្គដែលចូលចិត្តធ្វើការងារបោសសំអាតដោយមិនខ្លាចនឿយហត់។





絵②

ថ្ងៃមួយ  កូននេននោះត្រូវបាព្រះសង្ឃពឹងឲ្យធ្វើកិច្ចការមួយ។

ព្រះសង្ឃ៖  កូននេន  ជួយយកថ្នាំទៅឲ្យញោមប្រជាការពារនៅឯភូមិវាលភក់ផង។

កូននេន៖  កណាលោកតា។




全 第一

絵③

កូននេនបានដើរមកដល់ស្ពានឆ្លងទៅភូមិវាលភក់ ហើយបានឃើញក្រោមប្រជាការពារនៅក្រោយម្ខាងទៀត។

កូននេន៖ ចម្រើនពរញោម កំពុងធ្វើអីហ្នឹង?

ប្រជាការពារ៖ កណាតេជគុណ យាយស្ពានលឺស្ងូរតែរអ៊ូថាឈឺៗ អញ្ចឹងខ្ញុំកណាក៏ឈ្មៀតមកមើល
បន្តិចថាកើតអីដែរ។

កូននេនមើលទៅញោមស្ពានឃើញថាពិតជាមានរបួសដែលគួរឲ្យឈឺមែន។





絵④

នៅពេលដែលកំពុងមានសង្ឃដិការជាមួយញ្ញោមប្រជាការពារ កូននេនក៏នឹកឃើញថាលោកតាបានផ្ញើឲ្យយកថ្នាំមកឲ្យញ្ញោមប្រជាការពារ។

កូននេន៖ អូ! អាត្មាភ្លេចឲ្យនឹងថាលោកតាផ្ញើឲ្យយករបស់មកឲ្យញ្ញោម!





絵⑤

មានសង្ឃដិការហើយ កូននេនក៏បាននិមន្តឆ្លងស្ពានមកក្រោយម្ខាងទៀត។

ប្រជាការពារ៖ តេជគុណ កុំនិមន្តឆ្លងស្ពានអី!

យាយស្ពាន៖ (យំបណ្តើរហើយស្រែកថា) អូយ! ឈឺខ្លាំងណាស់!





絵⑥

ប្រជាការពារក៏បានចង្អុលទៅផ្លាកនៅច្រកស្ពាន។

ប្រជាការពារ៖ តេជគុណមានបានមើលផ្លាកនេះឬទេ?

កូននេន៖ អាត្មាភ្លេចមើលឲ្យឆឹង!




ស្ពានកំពុងជួសជុល
ហាមឆ្លង

絵⑦

កូននេនេ៖ និយាយអញ្ចឹងលោកតាផ្ញើឲ្យយកកន្ត្រកនេះមកឲ្យញោម។

ប្រជាការពារ៖ តេជគុណហេតុអ្វីមិនឆាប់មានសង្ឃដិការ!

កូននេនេ៖ ក្នុងកន្ត្រកហ្នឹងមានអ្វីខ្លះញោម?




安全第一

絵⑧

តើមានអ្វីខ្លះនៅក្នុងកន្ត្រក?

កូននេនេ៖ លោកតាថាជាថ្នាំ។

ប្រជាការពារ៖ ក្នុងកន្ត្រកមានទឹក ខ្សាច់ ស៊ីម៉ង់ និង ទឹកចិត្តរបស់អ្នកគ្រប់គ្នា។ នេះគឺជាថ្នាំសម្រាប់យាយស្ពាន!




ស៊ីម៉ង់
ខ្សាច់
និង

絵⑨

ប្រជាការពារនិងកូននេនប្រឹងប្រែងជួយគ្នាលាបថ្នាំឲ្យយាយស្ពាន។

កូននេនផ្សេងទៀតក៏បានមកជួយរួមគ្នាដើម្បីសំអាតយាយស្ពានឲ្យបានស្អាត។





絵⑩

បន្ទាប់ពីលាបថ្នាំនិងសំអាតរួច ស្នាមប្រេះបានបាត់ ស្បែករបស់យាយស្ពានក៏បាត់ជ្រួញក្លាយជាស្អាតរលូង សម្បីតែរោមភ្នែកក៏ដុះវែងជាងមុន។

យាយស្ពាន៖ ហា... មានអារម្មណ៍ថាស្រួលខ្លួនណាស់ លែងឈឺទៀតហើយ ដូចជាប្រែជាក្មេងវិញអញ្ចឹង។
អរគុណចៅប្រជាការពារ និងអរព្រះគុណតេជគុណគ្រប់អង្គ!

ប្រជាការពារ៖ ប៉ុន្នេះព្យាបាលយាយស្ពានបានមួយហើយ។ អរព្រះគុណតេជគុណ។ អាត្មាផ្តាំអរព្រះគុណលោកតាផង។





អ្វីដែលប្រជាការពារនិងកូននេនបានធ្វើនេះគឺហៅថា“ការជួសជុលនិងថែទាំស្ពាន”។
ការជួសជុលនិងថែទាំស្ពានគឺសំខាន់ណាស់សម្រាប់ធ្វើឲ្យតាស្ពានរស់រានមានជីវិតបានយូរ។
ចាប់ពីថ្ងៃនេះទៅ សង្ឃឹមថាអ្នកទាំងអស់គ្នានឹកឃើញពីរឿងនិទាននេះ និងគិតថាចង់ជួយជួសជុលនិង
ថែទាំស្ពានគ្រប់ពេលដែលឆ្លងកាត់ស្ពាន។



# សូមប្រើស្ពានដោយប្រុងប្រយ័ត្ន



表紙

រឿងនិទាននេះត្រូវបានបង្កើតឡើងដើម្បីឲ្យអ្នកទាំងអស់គ្នាស្គាល់អំពីស្ពាន។

សូមជូនរឿងនិទាន៖កុំឆ្លងស្ពាននេះ វគ្គជួសជុលនិងថែទាំ។

